# ការចិញ្ចឹមទាដោយប្រើចំណីផ្សំដោយខ្លួនឯង



មានបុរសម្នាក់ជាជនជាតិហ្វីលីពីនឈ្មោះ Leo Dator អាយុ ៨៣ឆ្នាំ គឺជាអ្នកចិញ្ចឹមទាយកពងម្នាក់ ដែលទទួលនៅជោគជ័យបំផុត គឺគាត់ខ្លួនឯងនិងក្រុមគ្រួសារគាត់បានចាប់ យកមុខរបរនេះតាំងពីឆ្នាំ ១៩៨៤ មកម្ល៉េះ ។

កសិកររូបនេះគាត់បញ្ចៀសបាននូវការប្រើចំណីពីរោងចក្រទាំងស្រុង គ្រប់ចំណីទាំងអស់ដែលបានផ្តល់ឲ្យទារបស់គាត់ គឺគាត់ផ្សំឡើងដោយខ្លួនឯង នេះក៏ព្រោះតែគាត់មិនមានលទ្ធភាពទិញចំណីទាំងនោះមកឲ្យទាគាត់ស៊ី ។ គ្មាននរណាម្នាក់ជឿទេថាគាត់អាចធ្វើដូច្នេះបាន ប៉ុន្តែកសិកររូបនេះនិងអ្វីដែលគាត់អាចធ្វើបានគឺជារឿងដោយឡែក ។

ឧស្សាហកម្មសាច់ទា និងពងទាគឺជាមុខរបរមួយកាក់កបគួរសមបើយើងអាច ចំណាយអស់តិចនិងអាចផ្សំចំណីឲ្យវាស៊ីបានគ្រប់គ្រាន់ ។ សព្វថ្ងៃនេះការចិញ្ចឹមទា គឺជារឿងមួយលំបាកសម្រាប់អ្នកខ្លះដែលមិនមានការពិសោធន៍ និងមិនមានលុយគ្រប់គ្រាន់សម្រាប់ទិញចំណីឲ្យវាស៊ី ម្លោះហើយ ចំនួនអ្នកចិញ្ចឹមបានថយចុះយ៉ាងច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។

នៅប្រទេសយើងការចិញ្ចឹមទា, យើងនិយមឲ្យវាស៊ីស្រូវ និងចំណីផ្សំខ្លះទៀត ប៉ុន្តែពេលនេះស្រូវឡើងថ្លៃ និងអ្វីៗក៏ថ្លៃធ្វើឲ្យការទិញស្រូវឲ្យជាចំណីសម្រាប់ទាមានការពិបាក ច្រើន ។

តាមការពិសោធន៍របស់លោក Leo Dator អ្នកចិញ្ចឹមទាដែលមានបទពិសោធន៍ជាង ២០ឆ្នាំកន្លងមកហើយបានបកស្រាយពីពិសោធន៍របស់គាត់ថា: កាលគ្រាចាប់ផ្តើមដំបូង ខ្ញុំបានព្យាយាមរកចំណីសម្រាប់ផ្តល់ឲ្យទារបស់ខ្ញុំចំនួន ១៥០០ក្បាល វាគឺជារឿងមួយយ៉ាងលំបាកសម្រាប់ខ្ញុំ ប៉ុន្តែខ្ញុំបានស៊ូទ្រាំតស៊ូ សម្រាប់ការប្រឈមមុខរឿងចំណីនោះ ដំបូងបំផុតខ្ញុំបានប្រមូលទិញដំឡូងឈើ ដំឡូងជ្វា ស្លឹក-ទងដំឡូងល្ហា យកមកចញ្ច្រាំឲ្យខ្ទេចរួចឲ្យទាទាំងនោះស៊ី ខ្ញុំបានប្រមូលទិញខ្ចៅ ខ្យង លៀស គ្រំតូចៗ មកកិនបំបែកឲ្យវាស៊ីជាបន្ថែម សូម្បីធាង ស្លឹក មើមត្រាវក៏ខ្ញុំបានសាកល្បងដែរ ហើយទាំងអស់នោះទទួលបានជោគជ័យបំផុត ចំណាយតិចបំផុត ហើយលទ្ធផលវិញគឺល្អជាងការឲ្យស៊ីចំណីផលិតពីរោងចក្រទៅទៀត ។

លោក Leo Dator បានឲ្យដឹងទៀតថា:មានភ្នាក់ងារតំណាងក្រុមហ៊ុនផលិតចំណីសត្វពីក្រុមហ៊ុននានា បានមកទាក់ទងខ្ញុំដោយបានប្រាប់ខ្ញុំពីប្រភេទចំណីដែលគេធ្វើ គឺប្រកប ដោយគុណភាព ល្អយ៉ាងនេះ ល្អយ៉ាងនោះមិនអាចប្រៀបស្មើជាមួយចំណីយ៉ាងសាមញ្ញរបស់ខ្ញុំឡើយ ។

- គ្រប់ដំឡូង ទាំងដំឡូងឈើ ដំឡូងជ្វា ដើមស្លឹកមើមគឺជាចំណីយ៉ាងសំខាន់បំផុតជំនួសឲ្យអ្វីៗផ្សេងទៀត ។ (បូករួមទាំងស្រូវ និងកន្ទក់)
- ខ្យងខ្ចៅ គ្រំ លៀស ខ្យងមាស គឺជាប្រភពជំនួយយ៉ាងសំខាន់សម្រាប់ឲ្យទាពងបានល្អ និងបានច្រើនថែមទាំងទៀងទាត់ទៀតផង
- ជន្លេន បើអាចចិញ្ចឹមបានសម្រាប់ផ្តល់ជាចំណីឲ្យទា គឺជាការមួយប្រសើរណាស់

សរុបសេចក្តីមកចំណីដែលខ្ញុំអាចផ្តល់ឲ្យទារបស់ខ្ញុំគឺមានដូចខាងក្រោមនេះ

- ស្រូវបណ្តុះឲ្យចេញជាពន្លក
- ដំឡូងឈើ ដំឡូងជ្វា ស្ងោ, ល្ពៅទុំកិនឲ្យខ្ទេច, សំបកចេកផ្អាប់
- ស្លឹកដំឡូងជ្វា ឲ្យស៊ីស្រស់ៗ
- ស្លឹកដំឡូងឈើ ស្ងោរ ឬត្រាំទឹកស្ករមួយយប់សិនទើបឲ្យស៊ី
- ខ្យងខ្ចៅ លៀស គ្រំ កូនកង្កែប ជន្លេន ប្រមូលទិញយកមកឲ្យវាស៊ី ពីអ្នកដែលគេដើររក
- ត្រាវកាត់ជាដុំៗហាល រួចកិនលាយជាមួយខ្យងខ្ចៅ កន្ទក់ឲ្យវាស៊ី
- ត្រីល្អិតៗស្រស់ៗ ដែលគេរកបានពីសមុទ្រ មួយសប្តាហ៍ស្ងោរឲ្យស៊ីម្តងលាយជាមួយកន្ទក់ ។

ចំណីទាំងអស់ខាងលើនេះ គឺល្អណាស់ល្អបំផុត ។ សព្វថ្ងៃនេះកសិដ្ឋានរបស់ខ្ញុំផ្គត់ផ្គង់សាច់ទា ពងទា ស្ទើរទាំងអស់ទៅក្នុងទីផ្សារនៃទីក្រុងម៉ានិល ព្រមទាំងមានបញ្ជូនទៅលក់ឲ្យប្រទេសផ្សេងៗ ក្នុងអាស៊ីផងដែរ វាគឺជាជោគជ័យមួយដោយប្រើប្រាស់វិធីផ្តល់ចំណីយ៉ាងសាមញ្ញបំផុត ។

ចាប់តាំងពីពេលចិញ្ចឹមដំបូងរហូតមកទល់ពេលនេះ ខ្ញុំមិនដែលជួបប្រទះបញ្ហាជំងឺរាតត្បាតទារបស់ខ្ញុំឡើយ កន្លែងចិញ្ចឹមត្រូវបានសំអាតជារៀងរាល់ថ្ងៃ ទឹកសម្រាប់ឲ្យទាលេងត្រូវបូមប្តូរមកច្រោះឲ្យស្អាត រួចទើបបង្ហូរចូលវិញ ការធ្វើបែបនេះវាជួយកាត់បន្ថយការឆ្លងជំងឺបានទាំងស្រុង ។

យើងបានភ្ញាស់ពងទាំងអស់ដែលយើងត្រូវការ យើងជ្រើសយកតែពូជបង្កាត់ល្អ មានពងច្រើន ហើយព្យាយាមរក្សាពូជនោះរហូតមកទល់ពេលសព្វថ្ងៃនេះ ។

ខ្ញុំមានពូជទាយ៉ាងល្អ ជាពូជទាដែលសម្រាំងនៅក្នុងកន្លែងនេះតែម្តង ។

ជារឿយៗពេក លោក Leo Dator ត្រូវបានគេអញ្ជើញឲ្យទៅធ្វើជាវាគ្មិន ពន្យល់ពីជោគជ័យរបស់គាត់ក្នុងការចិញ្ចឹមទាឲ្យដល់អ្នកបច្ចេកទេសចិញ្ចឹមទា និងអ្នកដែលមានបំណង ចិញ្ចឹមទាដោយគ្មានការលាក់របៀបអ្វីទាំងអស់, ដោយលោក Leo Dator មានជំនឿថា បើគេស្គាល់កសិដ្ឋានរបស់គាត់ និងរូបគាត់កាន់តែច្រើនវានឹងធ្វើឲ្យគាត់អាចលក់ទាបានកាន់តែច្រើន។

សព្វថ្ងៃនេះលោក Leo Dator មិនត្រឹមតែលក់សាច់ទារស់ឬ ធ្វើរួចប៉ុណ្ណោះទេតែក៏មានលក់ស៊ុតទា ស៊ុតទាប្រៃច្រើនប្រភេទ កូនទា ពងទាកូន និង អាហារខ្លះដែលផ្សំពីពងទាផងដែរ ។

វាជារឿងមួយដែលគួរត្រូវបានយកមកពិចារណា ហើយក៏ជាគំរូមួយយ៉ាងល្អផងដែរ ។

សព្វថ្ងៃនេះលោក Leo Dator មានពងទាពី ៣០.០០០-៥០.០០០ សម្រាប់លក់ឲ្យទីផ្សារដោយមានមេទាពងត្រឹមចំនួន ៥៥.០០០ ប៉ុណ្ណោះ ។ គាត់អាចស្មានពីចំនួនពងទាទទួលបានជាប្រចាំថ្ងៃ គឺមិនខុសពី ៥០.០០០ពងទេ បើវាធ្លាក់ទាបក៏មិនតិចជាង ៣០.០០០ដែរ ។

ខាងក្រោមនេះគឺជា ពត៌មានសម្រាប់ទំនាក់ទំនងទៅលោក Leo Dator (នៅហ្វីលីពីន)

Dator's Duck Farm

Brgy, Nanhaya, Victoria, Laguna

Tele (049) 5590574

Philipine

(ដកស្រង់ចេញពី ខេមបូឌាអេចប្រេសញូស៍)